តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជក្រម

នស/រកម/០៧២៦/០៧០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់ទាំងស្រុងកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ ៈ_**

មាត្រា២៥ មាត្រា២៦ មាត្រា៤៨ មាត្រា៤៩ មាត្រា៥០ មាត្រា៥៦ មាត្រា៥៧ មាត្រា៥៨ មាត្រា៥៩ មាត្រា៦០ មាត្រា៦១ មាត្រា៦៦ មាត្រា៦៧ មាត្រា៦៨ និងមាត្រា៦៩ នៃច្បាប់ស្តីពីផ្លូវថ្នល់ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា២៥ ៈ_ ថ្មី**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនលើផ្លូវថ្នល់ ត្រូវអនុវត្តតាមការកំណត់អំពីការផ្ទុកទម្ងន់ដូចមានចែងក្នុងមាត្រា២៦ថ្មីនៃច្បាប់នេះ និងត្រូវចូលត្រួតពិនិត្យដើម្បីថ្លឹងទម្ងន់នៅស្ថានីយថ្លឹងយានយន្តដែលស្ថិតនៅតាមបណ្តាញផ្លូវថ្នល់នីមួយៗ ព្រមទាំងត្រូវគោរពតាមបទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់។

បទដ្ឋានបច្ចេកទេសទំហំផ្លូវកម្រិតកំណត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

ការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៦ ៈ_ ថ្មី**

ការផ្ទុកទំនិញលើរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ដែលធ្វើចរាចរណ៍លើបណ្តាញផ្លូវថ្នល់ រួមមានផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងខេត្ត ផ្លូវជនបទ និងផ្លូវផ្សេងទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល មិនត្រូវឱ្យលើសទម្ងន់អតិបរមាសង្កត់លើភ្លៅនិងទម្ងន់សរុបអតិបរមារបស់យានដែលផលិតចេញពីរោងចក្រ និងត្រូវអនុវត្តតាមបញ្ញត្តិដូចខាងក្រោម៖

ក- ការកម្រិតទម្ងន់អតិបរមាសង្កត់លើភ្លៅរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក៖

- ៦(ប្រាំមួយ)តោន សម្រាប់ភ្លៅទោលដែលមានកង់២(ពីរ) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១១(ដប់មួយ)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៤(បួន) ស្ថិតនៅផ្នែកចង្កូតរថយន្ត
- ១០(ដប់)តោន សម្រាប់ភ្លៅទោលដែលមានកង់៤(បួន)
- ១៩(ដប់ប្រាំបួន)តោន សម្រាប់ភ្លៅភ្លោះដែលមានកង់៨(ប្រាំបី)
- ២៤(ម្ភៃបួន)តោន សម្រាប់ភ្លៅ៣(បី)ជិតគ្នាដែលមានកង់១២(ដប់ពីរ)។

ខ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្ត៖

- ១៦(ដប់ប្រាំមួយ)តោន សម្រាប់រថយន្តដែលមានភ្លៅ២(ពីរ) គឺភ្លៅទោលខាងមុខមានកង់២(ពីរ) និងភ្លៅទោលខាងក្រោយមានកង់៤(បួន)
- ២១(ម្ភៃមួយ)តោន សម្រាប់រថយន្តដែលមានភ្លៅ៣(បី) គឺភ្លៅភ្លោះខាងមុខមានកង់៤(បួន) និងភ្លៅទោលខាងក្រោយមានកង់៤(បួន)
- ២៥(ម្ភៃប្រាំ)តោន សម្រាប់រថយន្តដែលមានភ្លៅ៣(បី) គឺភ្លៅទោលខាងមុខមានកង់២(ពីរ) និងភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី)

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

- ៣០(សាមសិប)តោន សម្រាប់រថយន្តដែលមានភ្លៅ៤(បួន) គឺភ្លៅភ្លោះខាងមុខមានកង់៤(បួន) និងភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី)
- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តដែលមានភ្លៅ៥(ប្រាំ) គឺភ្លៅភ្លោះខាងមុខមានកង់៤(បួន) និងភ្លៅ៣(បី)ជិតគ្នាខាងក្រោយមានកង់១២(ដប់ពីរ)។

គ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងរ៉ឺម៉កៈ
- ៣៦(សាមសិបប្រាំមួយ)តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺរថយន្តមានភ្លៅ២(ពីរ) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅទោលខាងក្រោយមានកង់៤(បួន) និងរ៉ឺម៉កមានភ្លៅ២(ពីរ) ដែលភ្លៅទោលខាងមុខមានកង់៤(បួន) ភ្លៅទោលខាងក្រោយមានកង់៤(បួន)
- ៤៥(សែសិបប្រាំ)តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅ៥(ប្រាំ) គឺរថយន្តមានភ្លៅ៣(បី) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី) និងរ៉ឺម៉កមានភ្លៅ២(ពីរ) ដែលភ្លៅទោលខាងមុខមានកង់៤(បួន) ភ្លៅទោលខាងក្រោយមានកង់៤(បួន)
- ៥០(ហាសិប)តោន សម្រាប់រថយន្តសណ្តោងរ៉ឺម៉កដែលមានភ្លៅ៦(ប្រាំមួយ) គឺរថយន្តមានភ្លៅ៤(បួន) ភ្លៅភ្លោះខាងមុខមានកង់៤(បួន) ភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី) និងរ៉ឺម៉កមានភ្លៅ២(ពីរ) ដែលភ្លៅទោលខាងមុខមានកង់៤(បួន) ភ្លៅទោលខាងក្រោយមានកង់៤(បួន)។

ឃ- ការកម្រិតទម្ងន់សរុបអនុញ្ញាតអតិបរមារបស់រថយន្តសណ្តោងសឺមីរ៉ឺម៉កៈ
- ៣៥(សាមសិបប្រាំ)តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ៤(បួន) គឺរថយន្តមានភ្លៅ២(ពីរ) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅទោលខាងក្រោយមានកង់៤(បួន) និងសឺមីរ៉ឺម៉កភ្លៅភ្លោះមានកង់៨(ប្រាំបី)
- ៤០(សែសិប)តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ៥(ប្រាំ) គឺរថយន្តមានភ្លៅ២(ពីរ) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅទោលខាងក្រោយមានកង់៤(បួន) និងសឺមីរ៉ឺម៉កភ្លៅ៣(បី)ជិតគ្នាមានកង់១២(ដប់ពីរ)
- ៤៤(សែសិបបួន)តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ៥(ប្រាំ) គឺរថយន្តមានភ្លៅ៣(បី) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី) និងសឺមីរ៉ឺម៉កភ្លៅភ្លោះមានកង់៨(ប្រាំបី) និងស្នូលថ្លក់មានគម្លាតពីផ្ចិតភ្លៅទីមួយនៃសឺមីរ៉ឺម៉ក លើសពី៤,៥(បួនក្បៀសប្រាំ)ម៉ែត្រ
- ៤៩(សែសិបប្រាំបួន)តោន សម្រាប់រថយន្តសណ្តោងសឺមីរ៉ឺម៉កដែលមានភ្លៅ៦(ប្រាំមួយ) គឺរថយន្តមានភ្លៅ៣(បី) ភ្លៅទោលខាងមុខមានកង់២(ពីរ) ភ្លៅភ្លោះខាងក្រោយមានកង់៨(ប្រាំបី) និងសឺមីរ៉ឺម៉កមានភ្លៅ៣(បី)ជិតគ្នាមានកង់១២(ដប់ពីរ) និងស្នូលថ្លក់មានគម្លាតពីផ្ចិតភ្លៅទីមួយនៃសឺមីរ៉ឺម៉កមិនតូចជាង៨(ប្រាំបី)ម៉ែត្រ។

ការដឹកជញ្ជូនរបស់រថយន្តសណ្តោងរ៉ឺម៉កឬរថយន្តសណ្តោងសឺមីរ៉ឺម៉ក ដែលមានភ្លៅលើសពី៦(ប្រាំមួយ) ឡើងទៅ ត្រូវមានលិខិតអនុញ្ញាតពិសេសពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។ លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតពិសេសសម្រាប់ការដឹកជញ្ជូនរបស់រថយន្តសណ្តោងរ៉ឺម៉កឬរថយន្តសណ្តោងសឺមីរ៉ឺម៉ក ដែលមានភ្លៅលើសពី៦(ប្រាំមួយ) ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៤៨ ._ ថ្មី**

ទណ្ឌកម្មក្នុងបទល្មើសនៃច្បាប់នេះ រួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ អាជ្ញាបណ្ណ ការពិន័យអន្តរការណ៍ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

**មាត្រា៤៩ ._ ថ្មី**

ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតឬការព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណជាសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងអភិវឌ្ឍន៍ជនបទ។

ការពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចក្នុងព្រំប្រទល់ដែនដី នៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបម្រើការងារ។

**មាត្រា៥០ ._ ថ្មី**

មន្ត្រីអធិការកិច្ចផ្លូវថ្នល់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងមាត្រា៥២ដល់មាត្រា៧០នៃច្បាប់នេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍ មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ មន្ត្រីអធិការកិច្ចផ្លូវថ្នល់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងនៃបទល្មើស ហើយបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីដែលមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស មន្ត្រីអធិការកិច្ចផ្លូវថ្នល់ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសមកជាសម្បត្តិរដ្ឋតាមនីតិវិធីជាធរមាន។ ជនដែលមានប្រយោជន៍ពាក់ព័ន្ធ មានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរឹបអូសនេះតាមនីតិវិធីជាធរមាន។

បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍លើបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

**មាត្រា៥៦ ._ ថ្មី**

ជនណាដែលទទួលបានសិទ្ធិអនុវត្តគម្រោងអភិវឌ្ឍន៍ ឬគម្រោងថែទាំផ្លូវថ្នល់ ដោយៈ

១- យកថ្លៃប្រើប្រាស់ផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

២- មិនបានផ្សព្វផ្សាយជាសាធារណៈនូវថ្លៃប្រើប្រាស់ផ្លូវថ្នល់ ដែលទទួលបានការឯកភាពពីស្ថាប័នមានសមត្ថកិច្ចតាមការកំណត់ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០(ពីរលាន)រៀល

ហើយត្រូវឱ្យធ្វើការផ្សព្វផ្សាយឡើងវិញ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

៣- មិនព្រមបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់ នៅពេលមានកិច្ចព្រមព្រៀងជាមួយស្ថាប័នមានសមត្ថកិច្ចអំពីការបញ្ចុះថ្លៃប្រើប្រាស់ផ្លូវថ្នល់រួចរាល់ហើយ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០(ពីរលាន)រៀល។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៥៧ .- ថ្មី**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៦ថ្មី នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសតាមករណីដូចខាងក្រោម៖

១- ករណីល្មើសនឹងចំណុចទី១នៃមាត្រា៥៦ថ្មី នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០ ០០០ ០០០(ដប់លាន)រៀល។

២- ករណីល្មើសនឹងចំណុចទី២នៃមាត្រា៥៦ថ្មី នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល។

៣- ករណីល្មើសនឹងចំណុចទី៣នៃមាត្រា៥៦ថ្មី នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៥៨ .- ថ្មី**

សម្បទានិកឬក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ ដែលមិនសហការឬរារាំងមន្ត្រីមានសមត្ថកិច្ចដែលបំពេញតួនាទីដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០(ពីរលាន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៥៩ .- ថ្មី**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៥៨ថ្មី នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌទី១ នៃកថាខណ្ឌនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៦០.- ថ្មី**

អ្នកប្រើប្រាស់យានយន្តដឹកជញ្ជូនធុនធ្ងន់ ដែលដឹកជញ្ជូនទំនិញលើផ្លូវថ្នល់ ដោយ៖

១- មិនចូលថ្លឹងនៅស្ថានីយជញ្ជីងតាមបណ្តាញផ្លូវ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១ ០០០ ០០០(មួយលាន)រៀល។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសម្តងទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

២- ផ្ទុកទម្ងន់លើសពី៥(ប្រាំ)ភាគរយ ទៅ១០(ដប់)ភាគរយ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០០ ០០០(មួយសែន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ មិនលើសពី១០(ដប់)ថ្ងៃ។

៣- ផ្ទុកទម្ងន់លើសពី១០(ដប់)ភាគរយ ទៅ២០(ម្ភៃ)ភាគរយ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២០០ ០០០(ពីរសែន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ ចំនួន៦(ប្រាំមួយ)ខែ។

៤- ផ្ទុកទម្ងន់លើសពី២០(ម្ភៃ)ភាគរយ ទៅ៣០(សាមសិប)ភាគរយ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៣០០ ០០០(បីសែន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ ចំនួន៦(ប្រាំមួយ)ខែ។

៥- ផ្ទុកទម្ងន់លើសពី៣០(សាមសិប)ភាគរយ ទៅ៤០(សែសិប)ភាគរយ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥០០ ០០០(ប្រាំសែន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ ចំនួន៩(ប្រាំបួន)ខែ។

៦- ផ្ទុកទម្ងន់លើសពី៤០(សែសិប)ភាគរយ ទៅ៥០(ហាសិប)ភាគរយ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៨០០ ០០០(ប្រាំបីសែន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ ចំនួន១២(ដប់ពីរ)ខែ។

៧- ផ្ទុកទម្ងន់លើសពី៥០(ហាសិប)ភាគរយឡើងទៅ នៃទម្ងន់កម្រិតកំណត់ ត្រូវ៖

ក- រើទំនិញចេញ និងត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១ ០០០ ០០០(មួយលាន)រៀល ក្នុងទម្ងន់១(មួយ)តោន។

ខ- ដកនិងព្យួរបណ្ណបើកបរ ចំនួន១២(ដប់ពីរ)ខែ។

ក្នុងករណីមានអំពើល្មើសលើការផ្ទុកទម្ងន់សរុប និងអំពើល្មើសលើការផ្ទុកទម្ងន់អតិបរមានៃភ្លៅនោះ ត្រូវធ្វើការពិន័យអន្តរការណ៍ទាំងពីរករណី។

ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយចំពោះបទល្មើសដែលមានកំណត់ក្នុងចំណុចទី២ ដល់ចំណុចទី៧ខាងលើ តែនៅបន្តប្រព្រឹត្តបទល្មើសម្តងទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០(ពីរលាន)រៀល ក្នុងទម្ងន់១(មួយ)តោន និងត្រូវព្យួរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូនចំនួន១២(ដប់ពីរ)ខែ។

ចំណាយលើការលើកដាក់ទំនិញ ថ្លៃឈ្នួលកន្លែងទុកដាក់ថែទាំទំនិញនិងយានយន្ត ព្រមទាំងសេវាពាក់ព័ន្ធផ្សេងទៀត ជាបន្ទុករបស់ម្ចាស់យានយន្ត។

**មាត្រា៦១ .. ថ្មី**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៦០ថ្មី នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៦០ថ្មី នៃច្បាប់នេះ។ ក្នុងករណីដែលទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសម្តងទៀត ក្នុងរយៈពេល១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ ដូចមានចែងក្នុងវាក្យខណ្ឌទី១នៃកថាខណ្ឌនេះ។

**មាត្រា៦៦ .. ថ្មី**

ជនណាដែលធ្វើនូវការប្បលើដីចំណីផ្លូវសម្រាប់ធ្វើផ្លូវចេញចូលគេហដ្ឋាន អគារ រោងចក្រសហគ្រាស ឬកន្លែងផ្សេងៗ ដែលជាប់ផ្លូវថ្នល់ ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់បានត្រឹមត្រូវ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥០ ០០០(ប្រាំម៉ឺន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៦៧ .. ថ្មី**

ជនណាដែលធ្វើឱ្យផ្លូវថ្នល់រអិល ស្អិត ចាក់គំនរសំណង់ពង្រាយលើផ្លូវថ្នល់ ដាក់សម្ភារៈវត្ថុរាយប៉ាយលើផ្លូវថ្នល់ ដាក់តាំងសម្ភារៈឬផ្លាកសញ្ញាផ្សេងៗធ្វើឱ្យបាំងភ្នែកអ្នកបើកបរ ឬមួយបង្កឧបសគ្គដល់អ្នកថ្មើរជើងក្នុងការធ្វើដំណើរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥០ ០០០(ប្រាំម៉ឺន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៦៨ .. ថ្មី**

ជនណាដែលផ្លាស់ប្តូរ រុះរើ សរសេរ ឬធ្វើឱ្យខូចប្រយោជន៍ដល់ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ របងការពារសុវត្ថិភាព បង្គោលគីឡូម៉ែត្រ សញ្ញាបង្ហាញទិស ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០០ ០០០ (មួយសែន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រា៦៩ .. ថ្មី**

ជនណាប្រកបអាជីវកម្មលើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការថែទាំ និងការបើកមន្ទីរពិសោធន៍វិស័យផ្លូវថ្នល់ ដោយគ្មានអាជ្ញាបណ្ណ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល។

ក្នុងករណីដែលទទួលរងការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងរយៈពេល ១២(ដប់ពីរ)ខែ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។

**មាត្រាពីរ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ១១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២៦

ពរល.២៦០៧.៧០៧

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**